# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៩-៩-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៩០៣/២៩១ស្ដីពីការធ្វើវិសោធនកម្មព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា២ ចំណុចទី២ លេខរៀងទី ១១ ត្រូវបានកែសំរួលផ្ទៃដី តំបន់ដែនជំរកសត្វព្រៃរនាមដូនសំ ពីផ្ទៃទំហំ ១៧៨.៧៥០ ហិកតា មកត្រឹម ៤០.០២១ ហិកតា ៣១៦៦

២៩-៩-២០០៣ -ព្រះរាជក្រឹត្យនស/រកត/០៩០៣/២៩២ស្ដីពីការបំពាក់គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទចំនួន ៥៨ រូប ៣១៧០

២៩-៩-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៩០៣/២៩៣ ស្ដីពីការ ប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **នឹម ចំនួតារា** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ៣១៧៣

០២-១០-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/១០០៣/២៩៥ ស្ដីពីការតែងតាំងឯកឧត្តម **ជិន យន** បច្ចុប្បន្ន ប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុក ប្រធានរតនាគាជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ **រដ្ឋលេខាធិការ** ៣១៧៤

០៦-១០-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/១០០៣/២៩៦ ស្ដីពី :

១-ការផ្លាស់ប្ដូរឯកឧត្តម **នូ តឿង** ឧត្តមមន្ត្រីថ្នាក់លេខ ២ អភិបាលខេត្ត កំពង់ធំ អោយមកបំរើការនៅទីស្ដីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល ។

២-តែងតាំង ឯកឧត្តម **ណារំ ទុំ** ឧត្តមមន្ត្រីថ្នាក់លេខ ៦ ជា អភិបាលខេត្ត កំពង់ធំ ៣១៧៥

## II-ក្រុមប្រឹក្សាធម្មនុញ្ញ

០៣-១០-២០០៣ -លិខិតលេខ ២១/២០០៣ កបធ.សជណ ស្ដីពីការផ្ដល់មតិជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៣១៧៦

០៣-១០-២០០៣ -លិខិតលេខ ២២/២០០៣កបធ.សជណស្ដីពីការឆ្លើយតបលិខិតរបស់ឯកឧត្តម**ម៉ក ចណ្ណាឌី** តាមរយៈប្រធានរដ្ឋសភា ៣១៧៧

## III-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០១-១០-២០០៣ -អនុក្រឹត្យលេខ ៨៥៦ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៣១៧៨

០១-១០-២០០៣ -អនុក្រឹត្យលេខ ៨៥៧ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៣១៧៩

០១-១០-២០០៣ -អនុក្រឹត្យលេខ ៨៥៨ អនក្រ.តត ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣១៨០

០១-១០-២០០៣ -អនុក្រឹត្យលេខ ៨៥៩ អនក្រ.តត ស្ដីពីការតែងតាំងមុខងារនាយទាហាន ៣១៨១

០២-១០-២០០៣ -អនុក្រឹត្យលេខ ៨៦០ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរសក្តិនាយទាហាន ៣១៨២

០២-១០-២០០៣ -អនុក្រឹត្យលេខ ៨៦១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣១៨៤

០៣-១០-២០០៣ -អនុក្រឹត្យលេខ ៨៦២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣១៨៥

០៣-១០-២០០៣ -អនុក្រឹត្យលេខ ៨៦៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣១៨៦

០៣-១០-២០០៣ -អនុក្រឹត្យលេខ ៨៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៨៧

០៣-១០-២០០៣ -អនុក្រឹត្យលេខ ៨៦៥ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ ៣១៨៨

០៣-១០-២០០៣ -អនុក្រឹត្យលេខ ៨៦៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣១៨៩

## ២_សេចក្តីសំរេច

០៦-១០-២០០៣ -សេចក្តីសំរេចលេខ ៦៥ ស.ស.រ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៣១៩០

## III_ការងារបណ្តាក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០២-១០-២០០៣ -ប្រកាសលេខ ៥២៦ ប្រក.កសក ស្តីពីការកំណត់គំរូប្រភេទឧបករណ៍នេសាទឆក់ត្រី និង ឧបករណ៍នេសាទស្បៃមុងដែលត្រូវហាមឃាត់ ៣១៩១

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

០១-១០-២០០៣ -ប្រកាសលេខ ៩៣៤ អយក.ប្រក ស្តីពីការបើកសាលាបឋមសិក្សា ហ៊ុន សែន ចន្លក់ ជាសាលាបឋមសិក្សាពេញលក្ខណៈ ៣១៩៤

០៧-១០-២០០៣ -ប្រកាសលេខ ៩៦១ អយក.ប្រក ស្តីពីការបើកវិទ្យាល័យ ហ៊ុន សែន កងតាណឹង ស្ថិតនៅក្នុងឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម ៣១៩៥

០៧-១០-២០០៣ -ប្រកាសលេខ ៩៦២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ដូង ស្ថិតនៅក្នុងឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ៣១៩៦

០៧-១០-២០០៣ -ប្រកាសលេខ ៩៦៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន គ្រើល អណ្តូងពោធិ៍ ស្ថិតនៅក្នុង ឃុំអណ្តូងពោធិ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ៣១៩៧

០៧-១០-២០០៣ -ប្រកាសលេខ ៩៦៤ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ត្នោតជុំ ស្ថិតនៅក្នុង ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ៣១៩៨

០៧-១០-២០០៣ -ប្រកាសលេខ ៩៦៥ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ព្រៃគុយ ស្ថិតនៅក្នុង ឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ៣១៩៩

០៧-១០-២០០៣ -ប្រកាសលេខ ៩៦៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន ទួលដំណាក់ ស្ថិតនៅក្នុង ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ៣២០០

## គ

០៧-១០-២០០៣ -ប្រកាសលេខ ៩៦៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ម្រាក ស្ថិតនៅក្នុង ទួលគ្រើល ស្រុក ប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ៣២០១

០១-១០-២០០៣ -សារាចរណែនាំលេខ ០៦ អយក.សរណន ស្តីពីលក្ខណ្ឌនៃការទទួលស្គាល់បញ្ជីឈ្មោះនិស្សិត មធ្យមសិក្សាបច្ចេកទេស ឬ ឯកទេស ឬ ថ្នាក់បរិញ្ញាប័ត្ររង និង ថ្នាក់ បរិញ្ញាប័ត្រ ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា ៣២០២

### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

០២-១០-២០០៣ -សេចក្តីណែនាំលេខ ០៦ ក.ធ.ស សរណន ស្តីពីការគោរពប្រតិបត្តិសាសនាគ្រីស្ទ លើការងារ អប់រំក្រៅប្រព័ន្ធ ៣២០៥

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៣/២៩១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសបង្គាប់

**មាត្រា១៖**

ធ្វើវិសោធនកម្មព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា២ ចំណុចទី២ លេខរៀងទី១១ ត្រូវបានកែសំរួលផ្ទៃដីតំបន់ដែនជំរកសត្វព្រៃនាមដូនសំ ពីផ្ទៃដីទំហំ ១៧៨.៧៥០ ហិកតា មកនៅត្រឹម ៤០.០២១ហិកតា ។ ផែនទីព្រំប្រទល់ និងនិយាមការ នៃតំបន់ដែនជំរកសត្វព្រៃ ដែលបានកែប្រែថ្មី មានក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា២៖**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣៖**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

នស/រកត/០៩០៣/៣០៦ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី**
រដ្ឋមន្ត្រី ក្រសួងបរិស្ថាន
**ហត្ថលេខា**
**ម៉ុក ម៉ារ៉េត**

លេខ: ៦៣៤ច ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
សុខ ចិន្តាសោភា
ឥណ្ឌាំង តាន់

## ដែនជំរកសត្វព្រៃ រនាមដូនសំ Roniem Daun Sam Wildlife Sanctuary




ឧបសម្ព័ន្ធ ១ នៃព្រះរាជក្រឹត្យ លេខ :
នស/រកត/០៩០៣/២៦១ ចុះថ្ងៃទី ២៩/៩/០៣

*ឧបសម្ព័ន្ធ ២ នៃព្រះរាជក្រឹត្យ លេខ :*
*នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩/៩/០៣*

## និយាមការរបស់ដែនជំរកសត្វព្រៃរនាមដូនសំ

### តំបន់ I

| ល.រ | អាប់ស៊ីស X | អ័រដោនេ Y | ល.រ | អាប់ស៊ីស X | អ័រដោនេ Y |
|---|---|---|---|---|---|
| A | 236 000 | 1497 000 | E | 244 000 | 1470 000 |
| B | 244 000 | 1496 000 | F | 236 000 | 1478 000 |
| C | 245 000 | 1495 385 | G | 237 000 | 1478 000 |
| D | 244 000 | 1493 000 | H | 237 000 | 1491 000 |
| | | | I | 236 000 | 1491 000 |

### តំបន់ II

| ល.រ | អាប់ស៊ីស X | អ័រដោនេ Y | ល.រ | អាប់ស៊ីស X | អ័រដោនេ Y |
|---|---|---|---|---|---|
| J | 234 000 | 1462 000 | N | 253 000 | 1463 000 |
| K | 234 000 | 1476 690 | O | 253 000 | 1460 000 |
| L | 242 500 | 1468 000 | P | 251 000 | 1457 000 |
| M | 250 500 | 1467 000 | Q | 241 500 | 1457 000 |

### តំបន់ III

| ល.រ | អាប់ស៊ីស X | អ័រដោនេ Y |
|---|---|---|
| R | 234 000 | 1460 000 |
| S | 240 000 | 1455 500 |
| T | 238 000 | 1454 000 |
| U | 234 000 | 1454 000 |

# ព្រះរាជក្រឹត្យ

នស/រកត/១០០៣/២៩២

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៥៨រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចការងារបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | **អ៊ិន** | **ចាន់ថា** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ |
| ២-ឧត្តមសេនីយ៍ទោ | **ថោង** | **នៅ** | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៣-ឧត្តមសេនីយ៍ទោ | **សាញ់** | **ណេរ** | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៤-ឧត្តមសេនីយ៍ទោ | **ម៉ុន** | **ភេង** | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៥-ឧត្តមសេនីយ៍ទោ | **ហម** | **គីន** | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៦-ឧត្តមសេនីយ៍ទោ | **រស់** | **គាំសាន្ត** | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៧-ឧត្តមសេនីយ៍ទោ | **នី** | **ភេន** | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៨-ឧត្តមសេនីយ៍ទោ | **ឡុង** | **រិទ្ធីយ៉ា** | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៩-ឧត្តមសេនីយ៍ទោ | **ពុត** | **សំអោភ** | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ១០-ឧត្តមសេនីយ៍ទោ | **ខាំ** | **ចាន់** | ទីប្រឹក្សា ក្រសួងការពារជាតិ |

| | | |
|---|---|---|
| ១១-ឧត្តមសេនីយ៍ទោ | សាង សុខ | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ១២-ឧត្តមសេនីយ៍ទោ | សំ វណ្ណថន | នាយកខុទ្ទកាល័យ ក្រសួងការពារជាតិ |
| ១៣-ឧត្តមសេនីយ៍ទោ | មាស សំអុល | នាយក នាយកដ្ឋានបុគ្គលិក |
| ១៤-ឧត្តមសេនីយ៍ទោ | ម៉ម សុផាត | នាយក នាយកដ្ឋាននីតិកម្ម |
| ១៥-ឧត្តមសេនីយ៍ទោ | នេព ចំរើន | នាយក នាយកដ្ឋានភូមិសាស្ត្រ |
| ១៦-ឧត្តមសេនីយ៍ទោ | កែវ តាំ | នាយក នាយកដ្ឋានអធិការកិច្ចទូទៅ |
| ១៧-ឧត្តមសេនីយ៍ទោ | នំយ ថុល | ប្រធាន ស្ថាប័នតុលាការយោធា |
| ១៨-ឧត្តមសេនីយ៍ទោ | លី ដេត | អគ្គនាយករង អគ្គនាយកដ្ឋានភ័ស្តុភារ-ហិរញ្ញវត្ថុ |
| ១៩-ឧត្តមសេនីយ៍ទោ | ស៊ុំ សំណាង | អគ្គនាយករង អគ្គនាយកដ្ឋានភ័ស្តុភារ-ហិរញ្ញវត្ថុ និង ជានាយក នាយកដ្ឋានផ្គត់ផ្គង់ |
| ២០-ឧត្តមសេនីយ៍ទោ | យឹម សាវី | អគ្គនាយករង អគ្គនាយកដ្ឋានភ័ស្តុភារ-ហិរញ្ញវត្ថុ និង ជានាយក នាយកដ្ឋានប្រេងឥន្ធនៈ |
| ២១-ឧត្តមសេនីយ៍ទោ | ម៉េង ម៉ិនឡាយ | អគ្គនាយករង អគ្គនាយកដ្ឋានភ័ស្តុភារ-ហិរញ្ញវត្ថុ |
| ២២-ឧត្តមសេនីយ៍ទោ | មាស សាវ៉ន | អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និង ជានាយក នាយកដ្ឋានកិច្ចការយោធាស៊ីវិល |
| ២៣-ឧត្តមសេនីយ៍ទោ | ឡាយ ម៉ិនសុខ | អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និង ជានាយក នាយកដ្ឋានទាក់ទងអន្តរជាតិ |
| ២៤-ឧត្តមសេនីយ៍ទោ | ណឹម សុវត្ថិ | អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និង ជានាយក នាយកដ្ឋាននយោបាយផែនការ |
| ២៥-ឧត្តមសេនីយ៍ទោ | ប្រាក់ ម៉ារឌី | អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា |
| ២៦-ឧត្តមសេនីយ៍ទោ | ហេង ហុង | អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស |
| ២៧-ឧត្តមសេនីយ៍ទោ | ផន ណារ៉ា | អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស និង ជានាយក នាយកដ្ឋានបញ្ជូនសារ |
| ២៨-ឧត្តមសេនីយ៍ទោ | ផូ ផាន់ | អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស |
| ២៩-ឧត្តមសេនីយ៍ទោ | ឌៀ សុទ្ធ | អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស |
| ៣០-ឧត្តមសេនីយ៍ទោ | ប្រូចថ ម៉ិនថុល | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ៣១-ឧត្តមសេនីយ៍ទោ | ស៊ុន ចាន់ | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ៣២-ឧត្តមសេនីយ៍ទោ | នរោត្តម វ៉ាត់វ៉ាន់នី | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ៣៣-ឧត្តមសេនីយ៍ទោ | នុំ សម្បូរ | នាយកអធិការកិច្ច អគ្គបញ្ជាការដ្ឋាន |
| ៣៤-ឧត្តមសេនីយ៍ទោ | ធូ ស៊ីន | នាយកខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន |
| ៣៥-ឧត្តមសេនីយ៍ទោ | ម៉ក់ សារុន | នាយកទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន |
| ៣៦-ឧត្តមសេនីយ៍ទោ | ហ៊ុយ កែវ | នាយកមជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា អគ្គបញ្ជាការដ្ឋាន |
| ៣៧-ឧត្តមសេនីយ៍ទោ | ដាំ ដារ៉ារិទ្ធ | នាយកទីចាត់ការឃោសនា និង ពត៌មាន អគ្គបញ្ជា-ការដ្ឋាន |
| ៣៨-ឧត្តមសេនីយ៍ទោ | ឡាញ់ កៅ | មេបញ្ជាការ កងរថក្រោះ អគ្គបញ្ជាការដ្ឋាន |
| ៣៩-ឧត្តមនាវីទោ | មាស ថន | មេបញ្ជាការរង កងទ័ពជើងទឹក |
| ៤០-ឧត្តមនាវីទោ | ឌៀ ម៉ិញ | មេបញ្ជាការរង កងទ័ពជើងទឹក |
| ៤១-ឧត្តមនាវីទោ | សៅ សារិន | មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងទឹក |

| | | |
|---|---|---|
| ៤២-ឧត្តមសេនីយ៍ទោ | ច្រាក់ សុវណ្ណរា | នាយកសាលានាយទាហានចំរុះ អគ្គបញ្ជាការដ្ឋាន |
| ៤៣-ឧត្តមសេនីយ៍ទោ | ខឹម ជាសុឃឿន | នាយសេនាធិការរង និងជានាយកាិយាល័យទី៣ កងទ័ពជើងគោក |
| ៤៤-ឧត្តមសេនីយ៍ទោ | ទ្រាំ សនថុន | ប្រធានស្ថាប័នអយ្យការយោធា |
| ៤៥-ឧត្តមសេនីយ៍ទោ | យឹម សាញ់ | មេបញ្ជាការកងកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន |
| ៤៦-ឧត្តមសេនីយ៍ទោ | សែម សុវណ្ណនី | មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន |
| ៤៧-ឧត្តមសេនីយ៍ទោ | ពៅ ដារី | មេបញ្ជាការរង និង ជានាយសេនាធិការបញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន |
| ៤៨-ឧត្តមសេនីយ៍ទោ | ឈិន ចាន់ពណ៌ | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| ៤៩-ឧត្តមសេនីយ៍ទោ | គេច ឈួន | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| ៥០-ឧត្តមសេនីយ៍ទោ | ទេព្យ ពិសេន | មេបញ្ជាការរង និង ជានាយសេនាធិការ កងរាជ-អាវុធហត្ថ លើផ្ទៃប្រទេស |
| ៥១-ឧត្តមសេនីយ៍ទោ | គង់ នុនី | មេបញ្ជាការរង កងទ័ពជើងអាកាស |
| ៥២-ឧត្តមសេនីយ៍ទោ | ពិន ណារិទ្ធ | មេបញ្ជាការរង កងទ័ពជើងអាកាស |
| ៥៣-ឧត្តមសេនីយ៍ទោ | សោម សារុំម | មេបញ្ជាការរង កងទ័ពជើងអាកាស |
| ៥៤-ឧត្តមសេនីយ៍ទោ | វិសែស ទេព្យសុវត្ថារ | មេបញ្ជាការរង និង ជានាយសេនាធិការ កងទ័ពជើងអាកាស |
| ៥៥-ឧត្តមសេនីយ៍ទោ | ជុំ ចារក់ | នាយសេនាធិការរង និង ជានាយការិយាល័យទី ២ កងទ័ពជើងគោក |
| ៥៦-ឧត្តមសេនីយ៍ទោ | ទាន់ ចារីសេដ្ឋី | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៥៧-ឧត្តមសេនីយ៍ទោ | ហែម គ្រាញ់ | ទីប្រឹក្សា ក្រសួងការពារជាតិ |
| ៥៨-ឧត្តមសេនីយ៍ទោ | អ៊ុច សារ៉ាន | នាយកវិទ្យាស្ថានយោធាកម្ពុជា |

មាត្រា២ ៖ សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

នរស.០៣.០៩.៣០៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣

លេខ: ៧៤០ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៩០៣/២៩៣

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ត្រាស់ព្រះរាជនាន

ទំរពោះ

ឯកឧត្តម នឹម ច័ន្ទតារា

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣៤ស.០៣.០៩.២០០៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣*

លេខ: ២៤១ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ១០ ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារ៉ី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០៣/២៩៥

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជបរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ជិន ឃន** បច្ចុប្បន្នប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០៣.១០.៣០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៣

លេខ:៧៣៩ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ ១០ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាន់ តាន់**



# ព្រះរាជក្រឹត្យ

នស/រកត/១០០៣/២៩៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** ផ្លាស់ប្តូរភារកិច្ចឯកឧត្តម នូ គៀង ឧត្តមមន្ត្រី ថ្នាក់លេខ ២ អភិបាលខេត្តកំពង់ធំ អោយមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល ។

**មាត្រា ២:** តែងតាំងឯកឧត្តម **ណារិ ទុំ** ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ជាអភិបាលខេត្តកំពង់ធំ ។

**មាត្រា ៣:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ការ.០៣.១០.៣០៧

លេខ: ២៤៤១ ច ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ១៧ ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ 21/2003 កបធ.ស.ជ.ណ

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៣

**ជំរាបមក**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ** : ការស្នើផ្តល់មតិ

**យោង** : លិខិតរបស់ក្រសួងយុត្តិធម៌ លេខ ១០៤៩ អក.កយ/២០០៣ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមថា ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចទទួលសំណើរបស់ឯកឧត្តមមកពិនិត្យបានទេ ពីព្រោះការផ្តល់យោបល់ក្នុងលក្ខណៈបែបនេះ មិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឡើយ ។

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ 22/2003 កបធ.សជណ

រាជធានីភ្នំពេញ, ថ្ងៃទី 03 ខែ តុលា ឆ្នាំ 2003

**ជំរាបមក**

**ឯកឧត្តម ឯក វណ្ណឌី**

**តាមរយៈប្រធានរដ្ឋសភា**

**កម្មវត្ថុ** : សំណើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយឡើងវិញមាត្រា ៧៨ និង មាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ

**យោង** : លិខិតរបស់ឯកឧត្តម ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតរបស់ឯកឧត្តមដូចមានក្នុងកម្មវត្ថុ និងយោងខាងលើនេះរួចហើយ ប៉ុន្តែមិនអាចទទួលយកមកពិនិត្យពិភាក្សាបានទេ ដោយមូលហេតុដូចខាងក្រោម ÷

១- ជាគោលការណ៍ច្បាប់ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ (មាត្រា ១៤២ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ២៣ នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ) ។

លិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ២០/២០០៣ កបធ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣ ជាសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

២- ការសុំបកស្រាយមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ត្រូវមានការបញ្ជាក់អំពីបញ្ហាដែលមានកើតឡើងជាក់ស្ដែងក្នុងការអនុវត្តន៍ ឬ មូលហេតុត្រឹមត្រូវដែលនាំឱ្យមានការសុំបកស្រាយនោះ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចជាអ្នកធ្វើបទឧទ្ទេសនាមអំពីទ្រឹស្ដីបានឡើយ ។ សូមអានលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៩/២០០២ កបធ.សជណ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ដែលឆ្លើយទៅប្រធានរដ្ឋសភា ។

ម្យ៉ាងទៀត ក្រុមប្រឹក្សាធម្មនុញ្ញ សូមធ្វើការកត់សំគាល់ថា នៅក្នុងលិខិតរបស់ឯកឧត្តម មានអ្នកតំណាងរាស្ត្រខ្លះបានបាត់បង់គុណវុឌ្ឍិជាតំណាងរាស្ត្រអស់ហើយ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៤៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/ រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់ របស់រាជរដ្ឋាភិបាល

## <u>ស ម្រេ ច</u>

**មាត្រា ១** : តែងតាំង និង តម្លើងឋានន្តរសក្តិលោក **ប៉ុក សាលុយ** អនុមន្ត្រី ថ្នាក់លេខ៦ ជា **អភិបាលរងទី៣ ខេត្តបន្ទាយមានជ័យ** ដោយមានឋានន្តរសក្តិ **វរមន្ត្រី ថ្នាក់លេខ៦** ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី/សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ៩ ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>ចម្លងជូន</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ "ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៥៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/ រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់ របស់រាជរដ្ឋាភិបាល

**ស ម្រេ ច**

**មាត្រា ១** : តែងតាំងលោក **ម៉ែន សារី** អនុមន្ត្រី ថ្នាក់លេខ១៤ ជា **អភិបាលស្រុកថ្មពួក** ខេត្តបន្ទាយមានជ័យ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ "ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៥៨ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/ រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនីការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និង ថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់ របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឡុង ថាត** អោយមកទទួលមុខតំណែងជា **អភិបាលស្រុកកំចាយមារ** ខេត្តព្រៃវែង ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ "ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥៩. អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារនាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ំ រេ ច

**មាត្រា១ :** ត្រូវបានតែងតាំងមុខងារ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ជូនលោក ឧត្តមសេនីយ៍ទោ **ម៉ត់ សារ៉ុន** អត្តលេខ ០០០០៩១ នាយក ទីចាត់ការចលនូបត្ថម្ភ បច្ចុប្បន្នជា នាយរងសេនាធិការចំរុះ និងជានាយក ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិ **ថ្នាក់វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ទោ | **ឡាញ់** | **នី** | អត្តលេខ ០០១៦៧៧ | នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺននិងជួសជុលសំភារៈបញ្ជូនសារ |
| ២-វរសេនីយ៍ទោ | **ញ៉ូង** | **ខិនថន** | អត្តលេខ ០០១៦៧១ | នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺននិងជួសជុលសំភារៈបញ្ជូនសារ |
| ៣-វរសេនីយ៍ទោ | **សេង** | **សំអិត** | អត្តលេខ ០០៨៥៩៥ | នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺននិងជួសជុលសំភារៈបញ្ជូនសារ |
| ៤-វរសេនីយ៍ទោ | **យូ** | **សារ៉ែន** | អត្តលេខ ០០៨៦១១ | ជំនួយការ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាយ សាំងយុន** |
| ៥-វរសេនីយ៍ទោ | **នីច** | **ស៊ី** | អត្តលេខ ០០៨៦១២ | ជំនួយការ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាយ សាំងយុន** |

| | | | | |
|---|---|---|---|---|
| ៦-វរសេនីយ៍ទោ | យី | ភួយ | អត្តលេខ ០០៤០១៥ | ជំនួយការផ្ទាល់ ឯកឧត្តម អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា |
| ៧-វរសេនីយ៍ទោ | អ៊ូ | ខិ | អត្តលេខ ០០១២២០ | ជំនួយការ ឯកឧត្តម អគ្គមេបញ្ជាការ |
| ៨-វរសេនីយ៍ទោ | អិល | សំផន | អត្តលេខ ០០២៤១៧ | នាយករង សាលានាយទាហានចំរុះ អគ្គបញ្ជាការដ្ឋាន |
| ៩-វរសេនីយ៍ទោ | នេព | និរម្យ | អត្តលេខ ០០២០៨២ | មេបញ្ជាការរង កងពលតូចដឹកជញ្ជូន លេខ ៩០ ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន |
| ១០-វរសេនីយ៍ទោ | ម៉ត់ | សារឿន | អត្តលេខ ០០៤៩០១ | មេបញ្ជាការរង កងពលតូចដឹកជញ្ជូន លេខ ៩០ ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន |
| ១១-វរសេនីយ៍ទោ | ចាន់ | សាម្បេរ | អត្តលេខ ០០១៩៥១ | មេបញ្ជាការរង កងពលតូចដឹកជញ្ជូន លេខ ៩០ ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន |
| ១២-វរសេនីយ៍ទោ | សៀក | សុជាតិ | អត្តលេខ ០០៥២០៤ | នាយរង ការិយាល័យព្រំដែនគោក បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ១៣-វរសេនីយ៍ទោ | ចាន់ | ឈឿន | អត្តលេខ ០០១២៤៦ | មេបញ្ជាការរង កងកិត្តិយសត្រៃទ័ព ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន |
| ១៤-វរសេនីយ៍ទោ | អ៊ុន | សុយ៉េត | អត្តលេខ ០០២០២៥ | មេបញ្ជាការរង កងកិត្តិយសត្រៃទ័ព ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន |
| ១៥-វរសេនីយ៍ទោ | សូ | សារឿន | អត្តលេខ ០០៥២៩១ | ជំនួយការផ្ទាល់ ឯកឧត្តមឧត្តមសេនីយ៍ឯក **គន់ គីម** |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ តុលា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៦១ អនក្រ-តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃ ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃ ៣០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **រស់ វណ្ណា** ជាអគ្គនាយកសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) នៃក្រសួងសាធារណការ និង ដឹកជញ្ជូន សំរាប់អាណត្តិទី ២ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ [illegible] ៩ លា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៦៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា ១** :ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោក Teruo JINNAI ជាអ្នកឯកទេសកម្មវិធីវប្បធម៌របស់អង្គការវប្បធម៌វិទ្យាសាស្ត្រ និងការអប់រំសហប្រជាជាតិ ដែលមានគុណបំណាច់ដ៏ធំធេងក្នុងការចូលរួមចំណែកអភិរក្ស និង អភិវឌ្ឍន៍វប្បធម៌ នៅតំបន់អង្គរ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៦៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ០៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម ÷

**ក. មេដាយប្រាក់ការងារ :**

១-លោក **សួន សុឃីម** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

២-កញ្ញា **ខុន ចំនួនវត្តី** មន្ត្រី នៃនាយកដ្ឋានរដ្ឋបាលទូទៅ

**ខ. មេដាយសំរិទ្ធការងារ :**

-លោក **ទ្រី ម៉េងសាង** មន្ត្រី នៃនាយកដ្ឋានស្ថិតិប្រជាសាស្ត្រជំរឿន និង អង្កេត

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច

-ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៩ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា    ជាតិ  សាសនា  ព្រះមហាក្សត្រ

លេខ:...៧៦៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

### សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន នៃ សាធារណរដ្ឋកូរ៉េ ចំនួន ០៤រូប ដែលបាន ផ្តល់អំណោយជាម៉ាស៊ីនកុំព្យូទ័រ ចំនួន ១៣០ Sets សំរាប់រួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងកង យោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :-

១-**Mr. Heon Cheol Shin, CEO & Chairman , The Board of SK**

២-**Mr. Lim Jung Soo , Director of SK Telecom**

៣-**Venerable Sung Kwan , President of Sangka for engaged Buddhist ( Seoul, Republic of Korea )**

៤-**Mr. Kevin Jeong , President of HAN SIN Inc.**

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធ- ពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ករា ខែ ត.៧ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

176

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៦៥ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- តាមសំណូមពរចាំបាច់នៃការងារ

## សំរេច

**មាត្រា១ :** ត្រូវបានតែងតាំងមុខតំណែងលោកវរៈសេនីយ៍ឯក **មិត គីមហុង** អត្តលេខ ០៣៤៩ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានពត៌មានទូទៅ ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៣*

**ហ៊ុន សែន**

*កន្លែងទទួល*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

លេខ: ៧៦៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោកវរសេនីយ៍ឯក **ហេង ឫទ្ធី** នាយករងទីចាត់ការ អភិវឌ្ឍន៍ នៃ អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ ដែលមានស្នាដៃល្អ ក្នុងការទំនាក់ទំនងស្វែង រកជំនួយពីសប្បុរសជន នៃសាធារណរដ្ឋកូរ៉េ សំរាប់យកមកអភិវឌ្ឍន៍ កងយោធពលខេមរភូមិន្ទ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកង យោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ១៧ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៥ ស.ស.រ.

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើក ៩ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងបាលី សាធារណរដ្ឋឥណ្ឌូនេស៊ី ចាប់ពីថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣*

ហ៊ុន សែន

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៥២៦ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការកំណត់គំរូប្រភេទឧបករណ៍នេសាទឆក់ត្រី និង ឧបករណ៍នេសាទស្បៃមុងដែលត្រូវហាមឃាត់

### រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ សេចក្តីប្រកាសលេខ ០២ ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និង លុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យជលផល
- បានឃើញ សេចក្តីប្រកាសលេខ ០២ សប្រក ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការលុបបំបាត់ការប្រើឧបករណ៍នេសាទឆក់ត្រី និង ឧបករណ៍នេសាទស្បៃមុង

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkamon B V D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញ ប្រកាសលេខ ០២៨ កសក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ របស់ក្រសួងកសិកម្ម ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និង សមុទ្រ
- បានឃើញ ប្រកាសលេខ ២៥៩ ប្រក.កសក ចុះថ្ងៃ ទី ១២ ខែ សីហា ឆ្នាំ ២០០២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការហាមឃាត់ប្រើប្រាស់ឧបករណ៍ឆក់ត្រី ឧបករណ៍នេសាទអួនអូសក្រឡាញឹក និង ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ នៅក្នុងដែននេសាទទឹកសាបនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកដ្ឋានជលផល

## សម្រេច

**ប្រការ១** : កំណត់គំរូប្រភេទឧបករណ៍នេសាទឆក់ត្រី និង ឧបករណ៍នេសាទស្បៃមុងដែលត្រូវហាមឃាត់ដាច់ខាតដូចមានចែងខាងក្រោមនេះ :

ក- ឧបករណ៍នេសាទឆក់ត្រី

- ឧបករណ៍នេសាទឆក់ត្រីគ្រប់ប្រភេទ
- អាំងវែទ័រ ឬ ឧបករណ៍បំលែងចរន្តអគ្គិសនីពីចរន្តជាប់ទៅចរន្តឆ្លាស់ កម្លាំងលើសពី ២២០ V (ពីររយម្ភៃវ៉ុល)
- ដង និង ខ្សែឆក់ ។

ខ- ឧបករណ៍នេសាទស្បៃមុង

- លូស្បៃមុង ( សៃយឺនស្បៃមុង ឬ អ៊ុយស្បៃមុង)
- ឡុកស្បៃមុង
- ណស្បៃមុង
- ដាយស្បៃមុង
- ថ្នងស្បៃមុង
- អួនស្បៃមុងទឹកសាប
- របាំងស្បៃមុង
- អញ្ចងស្បៃមុង
- លបស្បៃមុង
- សាប ឬ យ៉ស្បៃមុង
- និង ឧបករណ៍នេសាទស្បៃមុងផ្សេងៗទៀតនៅក្នុងដែននេសាទទឹកសាប ។

**ប្រការ២** : លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង និង ប្រធានការិយាល័យជលផលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ចន្ទ័-សារុន

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៥៣ ❖ ៥៧

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ៩៣៤ អយក.ប្រក

# ប្រកាស
## ស្តីពីការបើកសាលាបឋមសិក្សា ហ៊ុន សែន ចន្លក់ ជាសាលាបឋមសិក្សាពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១អនក្រ.ប.ក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ២៣១ ក-អយក ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក គៀន ស្វាយ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៣ និងចំណារឯកភាពរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត **កណ្តាល** ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## ស ំ រេ ច

**ប្រការ១** : បើកសាលាបឋមសិក្សា **ហ៊ុន សែន ចន្លក់** ដែលមានទីតាំងស្ថិតនៅភូមិ **ចន្លក់** ឃុំ គគីរ ស្រុក **គៀនស្វាយ** ខេត្ត **កណ្តាល** ជាសាលាបឋមសិក្សាពេញលក្ខណៈចាប់ពីឆ្នាំសិក្សា ២០០៣-២០០៤ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ហ៊ុន សែន ចន្លក់** ត្រូវដឹកនាំដោយ នាយក១រូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត **កណ្តាល** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **គៀនស្វាយ** នាយកសាលាបឋមសិក្សា **ហ៊ុន សែន ចន្លក់** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០១ ខែ ៩ ៣ ឆ្នាំ ២០០៣
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលាខេត្ត កណ្តាល

**ដើម្បីជូនជ្រាបជាពត៌មាន**

-ដូចប្រការ ៤
-កាលប្បវត្តិ-ឯកសារ នា .បស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៨៧១ អយក.ប្រក

# ប្រកាស

ស្តីពីការបើកវិទ្យាល័យ ហ៊ុន សែន កងតាណឹង

ស្ថិតនៅក្នុងឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់អធិបាលស្រុកកងមាស លេខ ០៩សកម ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកវិទ្យាល័យដែលមានឈ្មោះថា : វិទ្យាល័យ « ហ៊ុន សែន កងតាណឹង » ស្ថិតនៅក្នុងឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី០៨ ខែតុលា ឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន "
- សាលាខេត្តកំពង់ចាម " ដើម្បីជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ៥៦៨ អយក. ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ដូង

ស្ថិតនៅក្នុងឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " ដូង " ស្ថិតនៅក្នុងឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី០៨ខែកញ្ញាឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ុំ សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តកំពង់ធំ" ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៩៦៣ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន គ្រើល អណ្តូងពោធិ៍ ស្ថិតនៅក្នុងឃុំអណ្តូងពោធិ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំអណ្តូងពោធិ៍ ស្រុកបារាយណ៍ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

### សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ហ៊ុន សែន គ្រើល អណ្តូងពោធិ៍ » ស្ថិតនៅក្នុងឃុំអណ្តូងពោធិ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និង នាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី០៧ខែតុលាឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ុម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តកំពង់ធំ" ដើម្បីជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៩៦៤ អយក.ប្រក

# ប្រ កា ស

## ស្ដីពីការបើកអនុវិទ្យាល័យ ត្នោតជុំ ស្ថិតនៅក្នុងឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្ដីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំត្នោតជុំ ស្រុកបារាយណ៍ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំ រេ ច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ត្នោតជុំ » ស្ថិតនៅក្នុងឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអត្រាការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី០៧ខែតុលា ឆ្នាំ ២០០៣

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តកំពង់ធំ" ដើម្បីជាពតិមាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៩៦៤ អយក.ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ព្រៃគុយ

ស្ថិតនៅក្នុងឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំព្រៃគុយ ស្រុកស្ទឹងសែន ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " ព្រៃគុយ " ស្ថិតនៅក្នុងឃុំព្រៃគុយ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី០៨ ខែតុលា ឆ្នាំ ២០០៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តកំពង់ធំ" ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា. មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៩៦៦ អយក.ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន ទួលដំណាក់

ស្ថិតនៅក្នុងឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំចុងដូង ស្រុកបារាយណ៍ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ហ៊ុន សែន ទួលដំណាក់ » ស្ថិតនៅក្នុងឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និង នាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ០៨ ខែ ១០ ឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពង់ធំ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ៥៧៤ អយក.ប្រក

# ប្រ កា ស

## ស្តីពីការបើកអនុវិទ្យាល័យ ម្រាក
## ស្ថិតនៅក្នុងឃុំទួលត្រើល ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំទួលត្រើល ស្រុកប្រាសាទបល្ល័ង្ក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**ស ំ រ េ ច**

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ម្រាក » ស្ថិតនៅក្នុងឃុំទួលត្រើល ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី០៨ខែតុលា ឆ្នាំ ២០០៣
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ុម សិទ្ធី

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តកំពង់ធំ " ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ : ០៦ អយក.សរណន

# សារាចរណែនាំ
# ស្តីពី
# លក្ខខណ្ឌនៃការទទួលស្គាល់បញ្ជីឈ្មោះនិស្សិត មធ្យមសិក្សាបច្ចេកទេស ឬ ឯកទេស ឬ ថ្នាក់បរិញ្ញាបត្ររង និង ថ្នាក់បរិញ្ញាបត្រ ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា

**យោង :** -ប្រកាសលេខ ៦៤១ អយក.ប្រក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០០ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីបទបញ្ជាក្នុងការចុះឈ្មោះចូលរៀន នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង ឯកជន

-ប្រកាសលេខ ៤៥០ អយក.ប្រក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០២ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីបទបញ្ជាជ្រើសរើសនិស្សិតអោយចូលរៀន នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា

-សារាចរណែនាំលេខ ០៦ អយក.សរណន ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០២ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីការបើកឯកទេសថ្មី ដេប៉ាតឺម៉ង់ថ្មី មហាវិទ្យាល័យថ្មី ថ្នាក់ថ្មី និង ការបើកសាខានៅតាមគ្រឹះស្ថានឧត្តមសិក្សា

កន្លងមកក្រសួងអប់រំ យុវជន និង កីឡា បានកត់សំគាល់ឃើញថា គ្រឹះស្ថានឧត្តមសិក្សាមួយចំនួន ក្រោយពីការប្រលង និង ជ្រើសរើសនិស្សិតថ្មីអោយចូលរៀន បានរូសរាន់បញ្ជូនបញ្ជីឈ្មោះនិស្សិតមកក្រសួងដើម្បីសុំការទទួលស្គាល់ ប៉ុន្តែក៏មានគ្រឹះស្ថានឧត្តមសិក្សាមួយចំនួនទៀតពុំបានយកចិត្តទុកដាក់លើបញ្ហានេះ ហើយពន្យារហូតដល់ចប់ឆ្នាំសិក្សាទើបបញ្ជូនបញ្ជីឈ្មោះនិស្សិតមកក្រសួង ដើម្បីសុំការទទួលស្គាល់។ ដើម្បីពង្រឹងការងារនេះ ក្រសួងអប់រំ យុវជន និង កីឡា សូមធ្វើការណែនាំដូចខាងក្រោម :

## I-សំណុំបែបបទស្នើសុំគ្រួចមាន :

### ក-សំរាប់ថ្នាក់ឆ្នាំទី១

១-លិខិតផ្សព្វផ្សាយដំណឹងប្រលងរឺ ជ្រើសរើសដែលក្នុងនោះមានកំនត់នូវលក្ខខណ្ឌ នៃការចុះឈ្មោះប្រលងរឺ ជ្រើសរើសអោយចូលរៀន វិញ្ញាសាប្រលង មុខវិជ្ជាដែលជ្រើសរើស និទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុប

ឃ

Re.Instistu

២-បញ្ជីឈ្មោះបេក្ខជនប្រលងវិ ជ្រើសរើស

៣-បញ្ជីវត្តមានបេក្ខជនដែលបានមកប្រលង

៤-គណៈកម្មការប្រលងនានាដែលក្រសួងអប់រំ យុវជន និង កីឡា បានទទួលស្គាល់

៥-បញ្ជីឈ្មោះបេក្ខជនដែលបានប្រលងជាប់វិ ជ្រើសរើសជាប់សំរេចដោយគណៈកម្មការប្រលងវិ ជ្រើសរើស

៦-របាយការណ៍ស្តីពីការប្រលងវិ ជ្រើសរើស

៧-បញ្ជីឈ្មោះនិស្សិតរៀននៅថ្នាក់ឆ្នាំទី១ ដែលត្រូវស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡាទទួលស្គាល់

៨-ក្នុងករណីនៅក្នុងបញ្ជីឈ្មោះនិស្សិតរៀននៅថ្នាក់ឆ្នាំទី១ ដែលត្រូវស្នើសុំក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់មានឈ្មោះនិស្សិតខុសពីបញ្ជីឈ្មោះបេក្ខជនដែលបានប្រលងជាប់វិ ជ្រើសរើសជាប់នោះគ្រឹះស្ថានសិក្សាត្រូវភ្ជាប់មកជាមួយបន្ថែមនូវឯកសារដែលពាក់ព័ន្ធទៅ នឹងនិស្សិតទាំងនោះ

៩-ពាក្យស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់បញ្ជីឈ្មោះនិស្សិតរៀននៅថ្នាក់ឆ្នាំទី១

ខ-**<u>សំរាប់និស្សិតថ្នាក់ឆ្នាំទី២</u>** :

១-ពាក្យស្នើសុំទទួលស្គាល់

២-សេចក្តីសំរេចរបស់ក្រុមប្រឹក្សាបច្ចេកទេសដែលសំរេចអោយនិស្សិតឆ្នាំទី១បានជាប់ឡើងថ្នាក់ឆ្នាំទី២ មុខជំនាញដដែល

៣-បញ្ជីឈ្មោះនិស្សិតដែលកំពុងរៀននៅថ្នាក់ឆ្នាំទី២ តាមមុខជំនាញ ដែលត្រូវស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់

៤-ក្នុងករណីមានឈ្មោះនិស្សិតនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី២ ខុសពីនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី១នាឆ្នាំកន្លងមកដែលត្រូវបានឡើងថ្នាក់សំរេចដោយក្រុមប្រឹក្សាបច្ចេកទេសនោះត្រូវភ្ជាប់មកជាមួយបន្ថែមនូវឯកសារដែលពាក់ព័ន្ធទៅនឹងនិស្សិតទាំងនោះ ។

គ-**<u>សំរាប់និស្សិតថ្នាក់ឆ្នាំទី៣</u>** :

១-ពាក្យស្នើសុំទទួលស្គាល់

២-សេចក្តីសំរេច របស់ក្រុមប្រឹក្សាបច្ចេកទេស ដែលសំរេចអោយនិស្សិតឆ្នាំទី២ បានជាប់ឡើងថ្នាក់ឆ្នាំទី៣ មុខជំនាញដដែល

៣-បញ្ជីឈ្មោះនិស្សិតដែលកំពុងរៀននៅថ្នាក់ឆ្នាំទី៣ តាមមុខជំនាញដែលត្រូវស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់

៤-ក្នុងករណីមានឈ្មោះនិស្សិត នៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី៣ ខុសពីនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី២នាឆ្នាំកន្លងមក ដែលត្រូវបានឡើងថ្នាក់សំរេចដោយក្រុមប្រឹក្សាបច្ចេកទេសនោះ ត្រូវភ្ជាប់មកជាមួយបន្ថែមនូវឯកសារដែលពាក់ព័ន្ធ ទៅនឹងនិស្សិតទាំងនោះ ។

**ឃ-សំរាប់និស្សិតថ្នាក់ឆ្នាំទី៥ :**

១-ពាក្យស្នើសុំទទួលស្គាល់

២-សេចក្តីសំរេច របស់ក្រុមប្រឹក្សាបច្ចេកទេស ដែលសំរេចអោយនិស្សិតឆ្នាំទី៣ បានជាប់ឡើងថ្នាក់ឆ្នាំទី៤ មុខជំនាញដដែល

៣-បញ្ជីឈ្មោះនិស្សិតដែលកំពុងរៀននៅថ្នាក់ឆ្នាំទី៤ តាមមុខជំនាញដែលត្រូវស្នើសុំអោយក្រសួងអប់រំ យុវជន និង កីឡា ទទួលស្គាល់

៤-ក្នុងករណីមានឈ្មោះនិស្សិតនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី៤ ខុសពីនៅក្នុងបញ្ជីឈ្មោះនិស្សិតថ្នាក់ឆ្នាំទី៣ នាឆ្នាំកន្លងមក ដែលត្រូវបានឡើងថ្នាក់សំរេចដោយក្រុមប្រឹក្សាបច្ចេកទេសនោះ ត្រូវភ្ជាប់មកជាមួយបន្ថែមនូវឯកសារដែលពាក់ព័ន្ធទៅនឹងនិស្សិតទាំងនោះ

## II-កាលបរិច្ឆេទបញ្ជូនសំណុំបែបបទ និង ការទទួលស្គាល់

គ្រឹះស្ថានសិក្សាត្រូវបញ្ជូន សំណុំបែបបទរបស់និស្សិតរៀននៅថ្នាក់ឆ្នាំទី១ អោយមកដល់នាយកដ្ឋានឧត្តមសិក្សា នៅ ក្រោយការប្រលងរឺជ្រើសរើសចំនួន ២៥ថ្ងៃ ដើម្បីសុំការទទួលស្គាល់ ។ ក្នុងករណីបញ្ជូនមកក្រោយការកំណត់នេះ ក្រសួងអប់រំ យុវជន និង កីឡា នឹងមិនទទួលស្គាល់បញ្ជីឈ្មោះនិស្សិតទាំងនោះឡើយ ។ ចំពោះសំណុំបែបបទរបស់និស្សិតថ្នាក់ឆ្នាំទី២ ទី៣ ទី៤ និង ថ្នាក់ឆ្នាំបន្តបន្ទាប់ គ្រឹះស្ថានសិក្សាត្រូវបញ្ជូនមកដល់នាយកដ្ឋានឧត្តមសិក្សា នៅក្រោយការចូលរៀនចំនួន ២០ថ្ងៃ ដើម្បីសុំការទទួលស្គាល់ ។ ក្នុងករណីបញ្ជូនមកក្រោយថ្ងៃកំនត់នេះ ក្រសួងអប់រំ យុវជន និង កីឡា នឹងមិនទទួលស្គាល់បញ្ជីឈ្មោះនិស្សិតទាំងនោះឡើយ ។

គ្រឹះស្ថានឧត្តមសិក្សាណា ដែលបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌខាងលើ នោះក្រសួងអប់រំ យុវជន និង កីឡា និង ចេញសេចក្តីបញ្ជាក់ទទួលស្គាល់លើបញ្ជីឈ្មោះនិស្សិតទាំងនោះ ។

បន្ទាប់ពីបានទទួលសារាចរណែនាំនេះគ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវអនុវត្តអោយបានត្រឹមត្រូវ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ុំ សិទ្ធី**

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីសូមជ្រាបជាពតិមាន"

-អគ.ឧបវ-អគ.របហ

-ន.រដ្ឋបាល-ន.បុគ្គលិក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក

"ដើម្បីជ្រាបជាពតិមាន"

-គ្រប់គ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទ

"ដើម្បីអនុវត្ត"

-កាលប្បវត្តិ

Re.Instistu

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ០៧ ក.ធ.ស ស.រ.ណ.ន

## សេចក្តីណែនាំ

## ស្តីពីការគោរពប្រតិបត្តិសាសនាគ្រីស្ទលើការងារអប់រំក្រៅប្រព័ន្ធ

**យោង:** -រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី១ អធិបតេយ្យភាព មាត្រា១វាក្យខ័ណ្ឌទី២ ព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍មិនចូលបក្សសម្ព័ន្ធ ។ ហើយជំពូកទី៣ មាត្រា ៣១ វាក្យខ័ណ្ឌ ២ " ប្រជាពលរដ្ឋខ្មែរមានភាពស្មើរគ្នាចំពោះមុខច្បាប់មានសិទ្ធិសេរីភាព និង ករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ " និងមាត្រា ៤៣ "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ " ។

-អនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា ។

-អនុក្រឹត្យលេខ ១៦៨ អនក្រ.តត ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២ ស្តីពីការរៀបចំសមាសភាពគណៈកម្មការជាតិអប់រំសំរាប់ទាំងអស់គ្នា ។

ក្រសួងធម្មការ និងសាសនា មានចំណាប់អារម្មណ៍ទៅលើសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ដែលកន្លងមកដល់បច្ចុប្បន្ននេះ ដែលអង្គការសមាគមក្រុមប្រឹក្សាសម្ព័ន្ធ សហព័ន្ធ និងព្រះវិហារឯករាជ្យនានា ដែលមានចរិតជាសាសនាគ្រីស្ទ ដូចដែលលិខិតស្រាយបំភ្លឺរបស់ឯកឧត្តមរដ្ឋមន្ត្រីស្តីទី លេខពិសេស ដែលបានផ្ទេរសិទ្ធិដោយរដ្ឋមន្ត្រី លេខ ៨១២ ក.ធ.ស ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០២ ពាក់ព័ន្ធទៅនឹងនិកាយប្រូតេស្តង់ខ្លះនោះបានបង្កឡើងហើយ តែងកើតមានជាញឹកញយ ដូចជាអំពើបំពានជំនឿសាសនារបស់ប្រជាពលរដ្ឋ, អំពើញុះញ៉ង់ប្រជាពលរដ្ឋខ្មែរឱ្យស្អប់វត្តអារ៉ាម ភិក្ខុសង្ឃ និងពុទ្ធសាសនា, អំពើអុចអាលប្រជាជនឱ្យបោះបង់ជំនឿសាសនាមួយទៅជឿសាសនាមួយទៀត តាមរយៈការផ្តល់សំភារៈលុយកាក់ ។ល។ ទាំងនេះគឺជាអំពើបំពានសិទ្ធិសេរីភាពជំនឿ ដែលមិនអាចអត់ឱន និងទុកឱ្យបន្តកើតមានតទៅទៀតបានឡើយ ។ ហើយម្យ៉ាងវិញទៀតសារាចរណែនាំស្តីពីការងារគ្រប់គ្រងកិច្ចការពាហិរ សាសនា លេខ ០១ ក.ធ.ស. ស.រ.ណ.ន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៣ ដែលអង្គការ សមាគម ក្រុមប្រឹក្សា សម្ព័ន្ធ សហព័ន្ធ និងព្រះវិហារឯករាជ្យ ដែលមានចរិតជាសាសនាគ្រីស្ទមិនបានគោរពទាល់តែសោះថែមទាំងបង្កឱ្យមានភាពអសកម្មមិនគោរពតាមស្មារតីនៃសារាចរនេះ ។

អាស្រ័យហេតុនេះ ក្រសួងធម្មការ និងសាសនា ដែលមានរូបខ្ញុំផ្ទាល់មានតួនាទីគ្រប់គ្រងការងារអប់រំសិក្សាក្រៅប្រព័ន្ធ យល់ឃើញ និងសំណូមពរដល់គ្រប់សាលាខេត្តក្រុង, គ្រប់មន្ទីរធម្មការ និង សាសនាខេត្តក្រុង, គ្រប់ស្ថាប័នអង្គភាពដែលមានការពាក់ព័ន្ធនេះ ត្រូវសហការឱ្យបានល្អក្នុងករណីខាងលើនេះ, មេត្តាយកចិត្តទុកដាក់ និងក្តាប់ឱ្យបានក្នុងការរួមចំណែកធានាឱ្យបាននូវការងារសណ្តាប់ធ្នាប់,សន្តិសុខសង្គម,ប្រឆាំងនិងគ្រប់មុខសញ្ញាភេរវកម្ម ដែលប្រទេសមួយចំនួននៅក្នុងបណ្តាប្រទេសអាស៊ានយើងមានបានជួបប្រទះរួចមកហើយនូវសកម្មភាពភេរវកម្មជ្រុលនិយមនេះ ។ ហើយម្យ៉ាងទៀតមានជនជាតិបរទេសមួយចំនួន ដែលមកបំពេញភារកិច្ចជាអង្គការមនុស្សធម៌មិនមែនរដ្ឋាភិបាល ដោយបានចុះអនុសារណៈនិងរាជរដ្ឋាភិបាលតាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិបានបំពានតួនាទីភារកិច្ចរបស់ខ្លួនមកជាបេសកកម្មសាសនាគ្រីស្ទ បង្រៀនអប់រំក្រៅប្រព័ន្ធស្នាក់អាស្រ័យនៅក្នុងវិហារ ឬការិយាល័យសាសនាគ្រីស្ទរបស់ខ្លួនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជាតិ និងសណ្តាប់ធ្នាប់សន្តិសុខសង្គម ហើយមិនបានគោរពនូវសេចក្តីណែនាំ លេខ ៨៦២/៩៤ ក.ធ.ស.ន.ស ចុះថ្ងៃទី ១២ ខែ១០ ឆ្នាំ ១៩៩៤ របស់ក្រសួងធម្មការនិង សាសនា ។

ដូចនេះ ក្រសួងមិនឯកភាពចំពោះការងារអប់រំក្រៅប្រព័ន្ធរបស់អង្គការ សមាគម ក្រុមប្រឹក្សា សម្ព័ន្ធ សហព័ន្ធ និងព្រះវិហារឯករាជ្យនានា ដែលមានចរិតជាសាសនាគ្រីស្ទទាំងនោះដូចដែលបានរៀបរាប់ខាងលើ និង សូមអំពាវនាវដើម្បីផលប្រយោជន៍ជាតិសណ្តាប់ធ្នាប់និងសន្តិសុខសង្គម សូមគ្រប់សាលាខេត្ត-ក្រុង គ្រប់មន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង មេត្តាផ្សព្វផ្សាយធ្វើយ៉ាងណាឱ្យអង្គការសមាគមក្រុមប្រឹក្សាសម្ព័ន្ធ សហព័ន្ធ និងព្រះវិហារ ឯករាជ្យនានា ដែលមានចរិត ជាសាសនាគ្រីស្ទ គោរពឱ្យបាននូវសារាចរ សេចក្តីណែនាំ និងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ជាពិសេសក្រសួងធម្មការ និងសាសនានៃព្រះរាជាណាចក្រកម្ពុជាយើង ។

ភ្នំពេញ, ថ្ងៃទី០២ ខែ តុលា ឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

អនុរដ្ឋលេខាធិការ

ដោក-ណារិន

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

" ដើម្បីគោរពជូនជ្រាប "

-គ្រប់សាលាខេត្ត-ក្រុង

-គ្រប់មន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង

-គ្រប់ក្រុមប្រឹក្សាគ្រីស្ទ

-គ្រប់ព្រះវិហារ កន្លែងថ្វាយបង្គំរបស់សាសនាគ្រីស្ទ

" ដើម្បីមុខការ "

-ឯកសារ-កាលប្បវត្តិ